ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ......០០៩......អ.ស.ហ.ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួងស្ថាប័ន លើកកម្ពស់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញប្រកាសលេខ ០០៤ អ.ស.ហ.ប្រក ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- យោងតាមតម្រូវការចាំបាច់របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

# សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងស្ថាប័នលើកកម្ពស់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដែលសរសេរកាត់ថា **ក.អ.ប.** ស្ថិតក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) ដើម្បីធានាប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការអនុវត្តយន្តការសម្របសម្រួលនិងកិច្ចសហការក្នុងក្របខណ្ឌអន្តរក្រសួងស្ថាប័ន ពាក់ព័ន្ធការអភិវឌ្ឍនិងការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ប្រកបដោយសហថាមភាព សហនវានុវត្តន៍ សហការទទួលខុសត្រូវ សិនិទ្ធភាព និងបរិយាបន្ន សំដៅ កសាងប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុរស់រវើក។

**ប្រការ២.-**

**ក.អ.ប.** មានសមាសភាពដូចខាងក្រោម÷

| | |
|---|---|
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. | ប្រធាន |
| - តំណាងធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| - តំណាងក្រសួងមហាផ្ទៃ | អនុប្រធាន |
| - តំណាងក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| - តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | អនុប្រធាន |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| - តំណាងក្រសួងយុត្តិធម៌ | អនុប្រធាន |
| - តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | អនុប្រធាន |
| - តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| - តំណាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល | អនុប្រធាន |
| - អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា | អនុប្រធាន |
| - អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា | អនុប្រធាន |
| - អគ្គនាយកនៃនិយ័តករសន្តិសុខសង្គម | អនុប្រធាន |
| - អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច | អនុប្រធាន |
| - អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម | អនុប្រធាន |
| - អគ្គនាយកនៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ | អនុប្រធាន |
| - តំណាងអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | សមាជិក |
| - ថ្នាក់ដឹកនាំនិងមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ស.ហ. | សមាជិក |

- ថ្នាក់ដឹកនាំនិងមន្ត្រីនិយ័តករក្រោមឱវាទ អ.ស.ហ. សមាជិក
- ថ្នាក់ដឹកនាំនិងមន្ត្រីក្រោមឱវាទក្រសួងស្ថាប័នពាក់ព័ន្ធ សមាជិក
- ប្រធានមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. សមាជិក។

**គ.អ.ប.** អាចមានសមាសភាពបន្ថែមពីក្រសួងស្ថាប័ន ឬអង្គភាពពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

សមាសភាពជាក់ស្តែងរបស់ **គ.អ.ប.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានក្រុមប្រឹក្សា អ.ស.ហ.។

**ប្រការ៣.-**

**គ.អ.ប.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម÷

- ជំរុញការស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- ជំរុញការរៀបចំ ការអនុវត្ត និងការធ្វើសុវត្ថិកម្មឬការធ្វើវិសោធនកម្មគោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក៏ដូចជាការផ្តួចផ្តើមគំនិតនវានុវត្តន៍ផ្សេងទៀត ពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- ជំរុញការប្រើប្រាស់ថ្នាលឌីជីថលគ្រឹះដែលមានស្រាប់និងការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះចាំបាច់ដទៃទៀតគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- ជំរុញការប្រើប្រាស់និងអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- ជំរុញការអភិវឌ្ឍនិងនវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារដែលរួមបញ្ចូលទាំងហិរញ្ញវត្ថុវិមជ្ឈការនិងបច្ចេកវិទ្យាដែលកំពុងលេចឡើង
- ជំរុញការលើកកម្ពស់អក្ខរកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- ចូលរួមទប់ស្កាត់ហានិភ័យបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- ចូលរួមផ្តល់មតិយោបល់និងវិភាគទានដល់ការរៀបចំកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលពាក់ព័ន្ធនឹងទិដ្ឋភាពបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- សហការនិងសម្របសម្រួលការងារជាមួយនឹងក្រសួងស្ថាប័ន អង្គភាព និងយន្តការពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងវិស័យឯកជន ពាក់ព័ន្ធនឹងការកសាង ការអភិវឌ្ឍ និងនិយ័តកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- ពិនិត្យនិងលើកសំណើដំណោះស្រាយលើបញ្ហាប្រឈមអន្តរវិស័យពាក់ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម និងបញ្ហាប្រឈមប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានក្រុមប្រឹក្សា អ.ស.ហ. និង
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាន **គ.អ.ប.**។

**ប្រការ៤.-**

**គ.អ.ម.** ត្រូវប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.អ.ម.**។ ក្នុងករណីប្រធាន **គ.អ.ម.** អវត្តមានឬមានករណីចាំបាច់ ប្រធាន **គ.អ.ម.** អាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំប្រជុំ។

អនុប្រធាន និងសមាជិកក្រុមការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.អ.ម.** ឬអនុប្រធាន **គ.អ.ម.** ករណីដែលប្រធាន **គ.អ.ម.** អវត្តមានឬមានការចាំបាច់។

ក្នុងករណីចាំបាច់ អនុប្រធាន ឬសមាជិក អាចចាត់តំណាងដែលមានសិទ្ធិសម្រេចដើម្បីចូលរួមកិច្ចប្រជុំជំនួស និងត្រូវជូនដំណឹងមកលេខាធិការដ្ឋាន នៃ **គ.អ.ម.**។

ប្រធាន **គ.អ.ម.** មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំនិងមន្ត្រី នៃក្រសួងស្ថាប័ន អង្គភាពពាក់ព័ន្ធ និងវិស័យឯកជនចូលរួមប្រជុំតាមការចាំបាច់។

មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. បំពេញតួនាទីជាលេខាធិការដ្ឋាន នៃ **គ.អ.ម.**។

**ប្រការ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. និងប្រធានអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៨ រោច ខែ កត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ